ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ បព ៦៤ /២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃការអញ្ជើញចូលរួមរបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន នៅក្នុងសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនីលើកទី៤៦ និងជំនួបទ្វេភាគី នៅទីក្រុងគីហ្គាលី នៃសាធារណរដ្ឋរ៉វ៉ាន់ដា

តបតាមការអញ្ជើញរបស់**ឯកឧត្តម Jean-Noël BARROT** រដ្ឋមន្ត្រីអឺរ៉ុប និងការបរទេស នៃសាធារណរដ្ឋបារាំង និង **ឯកឧត្តម Olivier J.P. NDUHUNGIREHE** រដ្ឋមន្ត្រីការបរទេស នៃសាធារណរដ្ឋរវ៉ាន់ដា **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនី (CMF) លើកទី៤៦ នៅទីក្រុងគីហ្គាលី នៃសាធារណៈរដ្ឋរវ៉ាន់ដា ក្រោមប្រធានបទ «**៣០ឆ្នាំក្រោយសន្និសីទទីក្រុងប៉េកាំង៖ ការចូលរួមចំណែករបស់ស្ត្រីនៅក្នុងបណ្តាប្រទេសហ្វ្រង់កូហ្វូន**» នៅថ្ងៃទី១៩-២០ ខែវិច្ឆិកា ឆ្នាំ២០២៥ ។

ស្របពេលនៃការអញ្ជើញចូលរួមសន្និសីទ CMF **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានអញ្ជើញបំពេញទស្សនកិច្ចផ្លូវការ និងមានជំនួបទ្វេភាគីជាមួយភាគីមិត្តនៃបណ្តាប្រទេសសមាជិកអង្គការ OIF ផងដែរ។

## I. ទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋរវ៉ាន់ដា

នៅថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២៥ **ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូទៅបំពេញទស្សនកិច្ចផ្លូវការនៅសាធារណរដ្ឋរវ៉ាន់ដា ដើម្បីពង្រឹងបន្ថែមទៀតនូវទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរ។

ក្នុងអំឡុងពេលនៃទស្សនកិច្ច **ឯកឧត្តម ប្រាក់ សុខុន** បានចូលជួបសម្តែងការគួរសមចំពោះ **ឯកឧត្តមបណ្ឌិត Justin Nsengiyumva** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋរវ៉ាន់ដា ព្រមទាំងបានជួបពិភាក្សាទ្វេភាគីជាមួយ **ឯកឧត្តម Olivier J.P. Nduhungirehe** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃសាធារណរដ្ឋរវ៉ាន់ដា។

ចំពោះកិច្ចពិភាក្សាទ្វេភាគីជាមួយ **ឯកឧត្តម Olivier J.P. Nduhungirehe** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃសាធារណរដ្ឋរវ៉ាន់ដា ភាគីទាំងពីរបានសម្តែងការពេញចិត្តចំពោះទំនាក់ទំនងទ្វេភាគីរវាងប្រទេសទាំងពីរដែលកំពុងរីកចម្រើន ចាប់តាំងពីការបង្កើតទំនាក់ទំនងការទូតក្នុងឆ្នាំ២០០៥ ជាពិសេសកិច្ចសហប្រតិបត្តិការក្នុងវិស័យហិរញ្ញវត្ថុ ដោយធនាគារជាតិនៃប្រទេសទាំងពីរបាន

ចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ និងវិស័យដឹកជញ្ជូនផ្លូវអាកាស ដែលភាគីទាំងពីរបាន ឯកភាពគ្នា និងគ្រោងនឹងចុះហត្ថលេខាឆាប់ៗខាងមុខ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរំលឹកពីប្រវត្តិសង្គ្រាម និងការឆ្លងកាត់របបប្រល័យពូជសាសន៍ និងបានចាត់ទុកសន្តិភាព និងការបង្រួបបង្រួមជាតិ ជាកត្តាមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។

ឯកឧត្តមរដ្ឋមន្ត្រីការបរទេសរ៉ាន់ដាបានថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ដែលបានផ្តល់កិច្ចសហប្រតិបត្តិការល្អ ក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស និងឆបោកតាមប្រព័ន្ធអ៊ិនធឺណែត។ ជាការឆ្លើយតប **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកឡើងថា ការជួញដូរមនុស្ស និងឆបោកតាមប្រព័ន្ធអ៊ិនធឺណែត ជាបញ្ហាសកល ទាមទារកិច្ចសហប្រតិបត្តិការជាអន្តរជាតិ ហើយរាជរដ្ឋាភិបាលកម្ពុជាបានបង្កើតគណៈកម្មការ ដើម្បីប្រយុទ្ធប្រឆាំងនឹងបទល្មើសនេះផងដែរ។

ភាគីទាំងពីរបានចុះអនុស្សរណៈនៃការយោគយល់គ្នាស្តីពីការបង្កើតកិច្ចពិគ្រោះយោបល់ទ្វេភាគី និងកិច្ចព្រមព្រៀងស្តីពីការលើកលែងទិដ្ឋាការសម្រាប់អ្នកកាន់លិខិតឆ្លងដែនការទូត និងផ្លូវការ។

នៅរសៀលថ្ងៃដដែល **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានចូលជួបសម្តែងការគួរសម ចំពោះ **ឯកឧត្តមបណ្ឌិត Justin Nsengiyumva** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋរ៉ាន់ដា។ ក្នុងអំឡុងពេលជួបសម្តែងការគួរសម **ឯកឧត្តមនាយករដ្ឋមន្ត្រី** បានកោតសរសើរចំពោះការពង្រឹងទំនាក់ទំនងរវាងប្រទេសទាំងពីរ។ **ឯកឧត្តមនាយករដ្ឋមន្ត្រី** បានបញ្ជាក់ថា ការចុះហត្ថលេខាលើឯកសារទ្វេភាគីទាំងពីរដោយរដ្ឋមន្ត្រីការបរទេស ទាំងពីរ នឹងបើកផ្លូវសម្រាប់ការពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការដែលមានស្រាប់ និងស្វែងយល់ពីវិស័យសក្តានុពលផ្សេងទៀតសម្រាប់ផលប្រយោជន៍ទៅវិញទៅមករបស់កម្ពុជា និងរ៉ាន់ដា។

ឆ្លើយតបនឹងបញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរៀបរាប់ស្រាយបំភ្លឺអំពីការពិតនៃជម្លោះ ដែលធ្វើឱ្យ **ឯកឧត្តមនាយករដ្ឋមន្ត្រី** បានយល់ច្បាស់។ ក្នុងន័យនេះ **ឯកឧត្តមនាយករដ្ឋមន្ត្រី** បានអរគុណចំពោះការផ្តល់ព័ត៌មានខាងលើនេះ។

## II. ការចូលរួមសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនី លើកទី៤៦

នៅក្នុងកិច្ចប្រជុំពេញអង្គ កាលពីថ្ងៃទី១៩ ខែវិច្ឆិកា **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ជាថ្មីពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការរួមចំណែកយ៉ាងសកម្ម ដើម្បីអនុវត្តសេចក្តីថ្លែងការណ៍នៃកិច្ចប្រជុំកំពូលនៅ Villers-Cotterêts ក្នុងគោលបំណងជំរុញហ្វ្រង់កូហ្វូនីឱ្យមានថាមវន្ត រួបរួម និងប្តេជ្ញាចិត្តដើម្បីបុព្វហេតុសន្តិភាព លទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍប្រកបដោយចីរភាព។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរំលឹកពីកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈរ ក្នុងការលើកកម្ពស់ភាសាបារាំង តាមរយៈការបន្ថែមមុខវិជ្ជាភាសាបារាំងនៅតាមវិទ្យាល័យរដ្ឋចំនួន ៥០ ការបណ្តុះបណ្តាលគ្រូបង្រៀនជាង ៣០០នាក់ ការបង្កើតកម្មវិធីសិក្សាភាសាបារាំងនៅតាមសាកលវិទ្យាល័យហ្វ្រង់កូហ្វូន និងការលើកកម្ពស់ពហុភាសាហ្វ្រង់កូហ្វូន ពិសេសតាមរយៈការផ្លាស់ប្តូររវាងយុវជន-យុវជននៅក្នុងតំបន់អាស៊ីអាគ្នេយ៍។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ថា យុវជន និងវប្បធម៌ គឺជាកម្លាំងចលករនៃការអភិវឌ្ឍ និងបានអំពាវនាវឱ្យពង្រឹងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ការគាំទ្រដល់សិល្បករក្នុងស្រុក និងការលើកកម្ពស់ការអប់រំបច្ចេកវិទ្យាឌីជីថល និងសហគ្រិនភាពនៅក្នុងក្របខណ្ឌហ្វ្រង់កូហ្វូន។

ចំពោះទិដ្ឋភាពភូមិសាស្ត្រនយោបាយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់សារជាថ្មីពីសារៈសំខាន់នៃកិច្ចសន្ទនា និងការដោះស្រាយជម្លោះដោយសន្តិវិធី ព្រមទាំងបានរំលេចអំពីតួនាទីសម្រុះសម្រួលដ៏សំខាន់របស់អង្គការ OIF។

នៅក្នុងកិច្ចពិភាក្សាស្តីពីតួនាទីស្ត្រីក្នុងបណ្តាប្រទេសប្រើប្រាស់ភាសាបារាំង **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកឡើងពីសមិទ្ធផលសំខាន់ៗ នៃសមភាពយេនឌ័រនៅប្រទេសកម្ពុជា តាមរយៈ៖

- ការលើកកម្ពស់លទ្ធភាពទទួលបានការអប់រំសម្រាប់ក្មេងស្រី។
- ការគាំទ្រ និងផ្តល់ការងារដល់ស្ត្រី និងសហគ្រិនភាពជាស្ត្រី។
- ការបង្កើនការចូលរួមរបស់ស្ត្រីនៅក្នុងផ្នែករដ្ឋបាលសាធារណៈ (៣៤%)។
- ការបញ្ជូនកងកម្លាំងមួកខៀវដែលជាស្ត្រីកម្ពុជា ប្រមាណ ៩០០នាក់ ចូលរួមប្រតិបត្តិការថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ចាប់តាំងពីឆ្នាំ២០០៦។

សេចក្តីអំពាវនាវរបស់ទីក្រុងគីហ្គាលី ត្រូវបានអនុម័តដោយជោគជ័យ ក្នុងកិច្ចប្រជុំពេញអង្គ ដែលសេចក្តីអំពាវនាវនេះ មានគោលបំណងពន្លឿនវឌ្ឍនភាពឆ្ពោះទៅរកសមភាពយេនឌ័រនៅក្នុងបណ្តាប្រទេសសមាជិកអង្គការ OIF។

នៅក្នុងកិច្ចប្រជុំចង្អៀត នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥ ក្រោមមូលបទ «តើអ្វីជាមហិច្ឆតារបស់អង្គការ OIF ក្នុងកំណែទម្រង់ទិដ្ឋភាពអន្តរជាតិ?» **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ពីភាពចាំបាច់ក្នុងការ៖

- រៀបចំគោលជំហរហ្វ្រង់កូហ្វូនី ជាសម្លេងមួយមានតុល្យភាព និងមានឥទ្ធិពលចំពោះបញ្ហាពិភពលោកចំបងៗ តួយ៉ាង បញ្ហាអាកាសធាតុ បញ្ញាសប្បនិម្មិត និងអភិបាលកិច្ចឌីជីថល ព្រមទាំងលើកកម្ពស់ពហុភាគីនិយមមួយប្រកបដោយបរិយាបន្ន ត្រឹមត្រូវ និងផ្តល់សារៈសំខាន់ដល់មនុស្សជាតិ។
- វិនិយោគក្នុងវិស័យអប់រំ បច្ចេកវិទ្យាឌីជីថល និងសេដ្ឋកិច្ចប្រកបដោយបរិយាបន្ន។
- ពង្រឹងសមត្ថភាពត្រៀមទុកមុន ផ្តល់ព័ត៌មានបន្ទាន់ និងសម្រុះសម្រួល ដើម្បីបង្ការជម្លោះ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានសង្កត់ធ្ងន់អំពីការអនុវត្តឱ្យបានពេញលេញនូវគុណតម្លៃស្នូលនៃធម្មនុញ្ញហ្វ្រង់កូហ្វូនី ដែលផ្តោតលើ សន្តិភាព លទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស ភាពចម្រុះ និងការអភិវឌ្ឍប្រកបដោយចីរភាព។

ពាក់ព័ន្ធនឹងបញ្ហាតំបន់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរាយការណ៍ពីភាពតានតឹងដែលនៅតែបន្តនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ខណៈការអនុវត្តសេចក្តីថ្លែងការណ៍រួមស្តីពីដំណោះស្រាយជម្លោះដោយសន្តិវិធី ដែលត្រូវបានចុះហត្ថលេខានៅទីក្រុងគូឡាឡាំពួរ កាលពីថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០២៥ រវាងនាយករដ្ឋមន្ត្រីកម្ពុជា និងថៃ ត្រូវបានប្រកាសឈប់អនុវត្តដោយភាគីថៃ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រជូនលោកជំទាវអគ្គលេខាធិការ OIF ចំពោះការគាំទ្រប្រកបដោយការស្ថាបនា និងឥតងាករេរបស់អង្គការ OIF ដោយបានរំលឹកថា សន្តិភាព អធិបតេយ្យភាព និងការគោរពការប្តេជ្ញាចិត្ត គឺជាតម្លៃមិនអាចចរចាបានឡើយ។

## III. ការផ្ទេរតំណែងប្រធានសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនីលើកទី៤៧ និងការប្រកាសពីកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី ២០

នៅរសៀលថ្ងៃទី២០ ខែវិច្ឆិកា **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានចូលកាន់តំណែងប្រធានសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនី (CMF) ជាផ្លូវការ ដោយប្រទេសបារាំងដែលជាប្រធានបច្ចុប្បន្ន និងជាម្ចាស់ផ្ទះកិច្ចប្រជុំកំពូលលើកទី១៩ នៅទីក្រុង Villers-Cotterêts បានផ្ទេរភាពជាប្រធានជូនកម្ពុជា ជាប្រទេសម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលលើកទី២០។

នៅក្នុងមតិស្វាគមន៍ក្នុងនាមជាប្រធានសន្និសីទ CMF **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងកក់ក្តៅចំពោះប្រទេសរវ៉ាន់ដាសម្រាប់ការរៀបចំ CMF លើកទី៤៦ ប្រកបដោយជោគជ័យ និងបានសាទរប្រទេសបារាំងសម្រាប់អាណត្តិជាប្រធាន CMF រយៈពេលពីរឆ្នាំ ព្រមទាំងបានថ្លែងអំណរគុណដល់លោកជំទាវអគ្គលេខាធិការ ចំពោះការបន្តប្តេជ្ញាចិត្តក្នុងការធ្វើឱ្យអង្គការ OIF ក្លាយជាស្ថាប័នមួយប្រកបដោយថាមវន្ត និងរក្សាបាននូវគុណតម្លៃហ្វ្រង់កូហ្វូនី។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ជាថ្មីម្តងទៀត ចំពោះការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់កម្ពុជាក្នុងការធានាឱ្យបាននូវភាពជោគជ័យនៃការរៀបចំសន្និសីទថ្នាក់រដ្ឋមន្ត្រីហ្វ្រង់កូហ្វូនីលើកទី៤៧ នៅថ្ងៃទី១៤ ខែវិច្ឆិកា និងកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ នៅថ្ងៃទី១៥ និង ១៦ ខែវិច្ឆិកា ឆ្នាំ២០២៦ នៅខេត្តសៀមរាប ប្រទេសកម្ពុជា។

## IV. ជំនួបទ្វេភាគី

ក្នុងឱកាសនៃការអញ្ជើញចូលរួមសន្និសីទ CMF **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជួបពិភាក្សាការងារជាមួយរដ្ឋមន្ត្រីការបរទេស នៃបណ្តាប្រទេសសមាជិករបស់អង្គការ OIF ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី រួមមាន៖

### 1) ប្រទេសបែលហ្ស៊ិក-ឯកឧត្តម Maxime PRÉVOT ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់អំពីសារៈសំខាន់នៃទំនាក់ទំនងជិតស្និទ្ធ និងប្រកបដោយទំនុកចិត្តរវាងប្រទេសកម្ពុជា និងបែលហ្ស៊ិក។ ថ្នាក់ដឹកនាំទាំងពីរបានស្វាគមន៍ចំពោះលទ្ធផលជាវិជ្ជមានក្នុងទំនាក់ទំនងទ្វេភាគី តាមរយៈកម្មវិធីកិច្ចសហប្រតិបត្តិការលើវិស័យសុខាភិបាល អប់រំ ការគាំពារសង្គម និងការដោះមីន។ ភាគីទាំងពីរក៏បានលើកឡើងពីជោគជ័យនៃកិច្ចប្រជុំពិគ្រោះយោបល់នយោបាយលើកទី១ និងបានឯកភាពរៀបចំកិច្ចប្រជុំបន្ទាប់ នៅទីក្រុងព្រុចសែលនៅឆ្នាំ ២០២៦។ ពាក់ព័ន្ធនឹងកិច្ចសហប្រតិបត្តិការផ្នែកតុលាការ រដ្ឋមន្ត្រីទាំងពីរបានអះអាងជាថ្មីនូវការប្តេជ្ញាចិត្តក្នុងការបញ្ចប់សេចក្តីព្រាង និងឈានដល់ការចុះហត្ថលេខាលើអនុសញ្ញាស្តីពីការផ្ទេរអ្នកទោសឱ្យបានឆាប់ក្នុងពេលខាងមុខ។ ឯកឧត្តម Maxime PRÉVOT បានបញ្ជាក់ពីបំណងក្នុងការចូលរួមកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ នៅខេត្តសៀមរាបក្នុងឆ្នាំ២០២៦។

### 2) ប្រទេសបារាំង-លោកជំទាវ Éléonore CAROIT រដ្ឋមន្ត្រីប្រតិភូទទួលហ្វ្រង់កូហ្វូនី

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជម្រាបពីវឌ្ឍនភាពនៃការត្រៀមរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ ដែលគ្រោងធ្វើឡើងនៅឆ្នាំ២០២៦ នៅខេត្តសៀមរាប។ លោកជំទាវរដ្ឋមន្ត្រីប្រតិភូបានបញ្ជាក់

ពីការអញ្ជើញចូលរួមកិច្ចពិគ្រោះយោបល់នយោបាយរវាងប្រទេសទាំងពីរនៅពេលខាងមុខ និងបានបញ្ជាក់បំណងមកទស្សនកិច្ចនៅកម្ពុជានាពេលខាងមុខ ដើម្បីចូលរួមចំណែកដល់ការត្រៀមរៀបចំកិច្ចប្រជុំកំពូល។

**3) រដ្ឋកេបិក-ឯកឧត្តម Christopher SKEETE រដ្ឋមន្ត្រីទទួលបន្ទុកទំនាក់ទំនងអន្តរជាតិ និងហ្វ្រង់កូហ្វូនី**

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអះអាងនូវការប្តេជ្ញាចិត្តក្នុងការពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយរដ្ឋកេបិច ពិសេសក្នុងក្របខណ្ឌហ្វ្រង់កូហ្វូនី ព្រមទាំងបានស្នើរដ្ឋកេបិកជួយកៀរគរក្រុមហ៊ុន និងភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមគាំទ្រព្រឹត្តិការណ៍ ភូមិហ្វ្រង់កូហ្វូនី និង FrancoTech។ ថ្នាក់ដឹកនាំទាំងពីរក៏បានបង្ហាញពីឆន្ទៈដើម្បីស្វែងរកកាលានុវត្តភាពបន្ថែមទៀត ក្នុងការពង្រីកកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យ។

**4) ស្វីស-ឯកឧត្តម Ignazio CASSIS រដ្ឋមន្ត្រីការបរទេសនៃសហព័ន្ធស្វីស**

រដ្ឋមន្ត្រីទាំងពីរបានសម្តែងការពេញចិត្តចំពោះការរីកចម្រើនផ្នែកទំនាក់ទំនងទ្វេភាគី និងបានពិភាក្សាគ្នាអំពីមធ្យោបាយពង្រឹងកិច្ចសហប្រតិបត្តិការឱ្យកាន់តែស៊ីជម្រៅ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណសហព័ន្ធស្វីសចំពោះជំនួយអភិវឌ្ឍន៍ ក្នុងវិស័យសុខាភិបាល ការដោះមីន វប្បធម៌ និងអភិបាលកិច្ចមូលដ្ឋាន។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងការដឹងគុណចំពោះការលះបង់របស់លោកវេជ្ជបណ្ឌិត Beat RICHNER និងការបន្តគាំទ្ររបស់សហព័ន្ធស្វីសដល់មន្ទីរពេទ្យគន្ធបុប្ផា។ ភាគីស្វីសបានគូសបញ្ជាក់ពីគាំទ្រកម្ពុជាយ៉ាងពេញទំហឹងក្នុងការរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីលើកទី២០ ជាពិសេស ព្រឹត្តិការណ៍ FrancoTech។

ក្នុងបណ្តាជំនួបខាងលើ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជម្រាបជូនភាគីមិត្ត អំពីការវិវត្តនៃស្ថានការណ៍ថ្មីៗនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ និងបានបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងបុព្វហេតុសន្តិភាព ការគោរពកិច្ចព្រមព្រៀងទ្វេភាគី និងការដោះស្រាយជម្លោះដោយសន្តិវិធី។

ថ្ងៃសុក្រ ៨កើត ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២៥